សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance

**លិខិតចំហរបស់អង្គការសារព័ត៌មាន និងសិទ្ធិមនុស្សចំនួន៧៤ ជំរុញឱ្យមេដឹកនាំប្រទេសក្នុងតំបន់អាស៊ី ដោះលែងអ្នកសារព័ត៌មានដែលកំពុងជាប់ឃុំ**

ជូនចំពោះ៖

នាយករដ្ឋមន្ត្រីកម្ពុជា លោក ហ៊ុន សែន

ប្រធានាធិបតីសាធារណរដ្ឋប្រជាមានិតចិន លោក ស៊ី ជីនភីង (Xi Jinping)

នាយករដ្ឋមន្ត្រីឥណ្ឌា ណារិនដ្រា ម៉ូឌី (Narendra Modi)

ទីប្រឹក្សារដ្ឋមីយ៉ាន់ម៉ា លោកស្រី អ៊ុងសាន ស៊ូជី (Aung San Suu Kyi)

នាយករដ្ឋមន្ត្រីប៉ាគីស្ថាន លោក អ៊ីមរ៉ាន់ ខាន់ (Imran Khan)

ប្រធានាធិបតីហ្វីលីពីន លោក រ៉ូឌ្រីហ្គោ ឌូទែរតេ (Rodrigo Duterte)

ប្រធានាធិបតីវៀតណាម លោក ង្វៀន ហ្វូជុង (Nguyen Phu Trong)

ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០

*បានផ្ញើជូនតាមអ៊ីមែល*

ឯកឧត្តម លោកជំទាវជាទីគោរព!

យើងខ្ញុំជាស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ អង្គការសេរីភាពសារព័ត៌មាន និងសិទ្ធិមនុស្សចំនួន៧៤ ដែលបានចុះហត្ថលេខារួមគ្នា សូមអំពាវនាវដល់រដ្ឋាភិបាលរបស់ឯកឧត្តម លោកជំទាវ ឱ្យដោះលែងអ្នកសារព័ត៌មានដែលកំពុងជាប់ឃុំក្នុងអំឡុងពេលដែលជំងឺកូវីដ១៩កំពុងរាតត្បាតជាសកល។

នៅថ្ងៃទី ៣០ ខែមីនា គណៈកម្មាធិការការពារអ្នកសារព័ត៌មាន (The Committee to Protect Journalists) បានចាប់ផ្តើមយុទ្ធនាការមួយដែលមានឈ្មោះថា #FreeThePress (ដោះលែងអ្នកសារព័ត៌មាន) ដោយដាក់ញត្តិ និងផ្សព្វផ្សាយលិខិតចំហទៅកាន់មេដឹកនាំពិភពលោកជំរុញឱ្យមានការដោះលែងជាបន្ទាន់នូវអ្នកសារព័ត៌មានទាំងអស់ដែលកំពុងជាប់ពន្ធនាគារដោយសារការបំពេញការងាររបស់ពួកគេ។ ដោយមើលឃើញពីចំនួនដ៏គួរឱ្យភ្ញាក់ផ្អើលនៃអ្នកសារព័ត៌មានដែលត្រូវបានដាក់ពន្ធនាគារនៅទូទាំងទ្វីបអាស៊ី យើងខ្ញុំសូមអំពាវនាវម្តងទៀតដល់រដ្ឋាភិបាលក្នុងពេលដែលមានការព្រួយបារម្ភយ៉ាងខ្លាំងពីបញ្ហាសុខភាពសាធារណៈបែបនេះ។

យោងតាមការធ្វើជំរឿនក្នុងពន្ធនាគារប្រចាំឆ្នាំចុងក្រោយបំផុតរបស់គណៈកម្មាធិការការពារអ្នកសារព័ត៌មាន ដែលបានធ្វើកាលពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩ មានអ្នកសារព័ត៌មានយ៉ាងហោចណាស់ចំនួន៦៣នាក់ជាប់ក្នុងពន្ធនាគារក្នុងតំបន់អាស៊ី ដែលក្នុងនោះ៤៨នាក់នៅប្រទេសចិន ១២នាក់នៅប្រទេសវៀតណាម ២នាក់នៅប្រទេសឥណ្ឌា និងម្នាក់ទៀតនៅប្រទេសមីយ៉ាន់ម៉ា។

ការស្រាវជ្រាវរបស់គណៈកម្មាធិការការពារអ្នកសារព័ត៌មាន បានឱ្យដឹងថា គិតត្រឹមថ្ងៃទី ៣១ ខែមីនា យ៉ាងហោចណាស់មានអ្នកកាសែត ៥ នាក់ត្រូវបានដោះលែង ដែលក្នុងនោះ ៤ នាក់នៅប្រទេសចិន និងម្នាក់ទៀតនៅប្រទេសវៀតណាម។ ទោះយ៉ាងណាក៏ដោយ យ៉ាងហោចណាស់មានអ្នកកាសែត ៥ នាក់ផ្សេងទៀត ត្រូវបានចាប់ខ្លួនចាប់តាំងពីថ្ងៃទី ១ ធ្នូមក រួមមានលោក សុវណ្ណ រិទ្ធី នៅប្រទេសកម្ពុជា អ្នកសារព័ត៌មានឈ្មោះ Chen Jiaping នៅប្រទេសចិន Gautam Navlakha នៅប្រទេសឥណ្ឌា Mir Shakil-ur-Rahman នៅប៉ាគីស្ថាន និង Frenchiemae Cumpio នៅប្រទេសហ្វីលីពីន។

មាត្រា១៩នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សធានាដល់មនុស្សគ្រប់រូបនូវសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិដោយគ្មានការជ្រៀតជ្រែក និងសិទ្ធិក្នុងការស្វែងរក ទទួល និងចែកចាយព័ត៌មាន ក៏ដូចជាមតិយោបល់របស់ពួកគេតាមរយៈប្រព័ន្ធផ្សព្វផ្សាយទាំងអស់ដោយគ្មាន ព្រំដែន។

យោងតាមអង្គការសុខភាពពិភពលោក «ពលរដ្ឋដែលត្រូវបានដកហូតសិទ្ធិសេរីភាព និងកំពុងរស់នៅ ឬធ្វើការក្នុងបរិយាកាសបិទជិត ទំនងជាងាយរងគ្រោះដោយសារជំងឺកូវីដ១៩ ជាងពលរដ្ឋទូទៅ។»

សម្រាប់អ្នកសារព័ត៌មានដែលកំពុងជាប់ពន្ធនាគារក្នុងបណ្តាប្រទេសរងផលប៉ះពាល់ដោយជំងឺកូវីដ១៩ បញ្ហាសេរីភាពក្នុងពេលបច្ចុប្បន្ននេះគឺជាបញ្ហាប៉ះពាល់ដល់អាយុជីវិត។ អ្នកសារព័ត៌មានដែលកំពុង

ជាប់ពន្ធនាគារ មិនអាចគ្រប់គ្រងលើមជ្ឈដ្ឋានជុំវិញខ្លួន មិនអាចជ្រើសរើសនៅដាច់ដោយឡែកពីគេ ហើយជាញឹកញាប់មិនអាចទទួលបានការថែទាំសុខភាពចាំបាច់បានឡើយ។

អ្នកសារព័ត៌មានទាំងនេះជាច្រើនត្រូវបានឃុំឃាំងដោយមិនបានជំនុំជម្រះក្នុងរយៈពេលដ៏យូរ និងកំពុងទទួលរងនូវបញ្ហាសុខភាពដោយសារសុខភាពទ្រុឌទ្រោម ភាពចង្អៀតណែនក្នុងពន្ធនាគារ ដែលនៅទីនោះពួកគេបានឆ្លងនូវជំងឺគ្រុនចាញ់ របេង និងជំងឺដទៃទៀត។

យើងសូមជំរុញឱ្យដោះលែងអ្នកសារព័ត៌មានដែលជាប់ពន្ធនាគារទាំងអស់នៅក្នុងប្រទេសរបស់ឯកឧត្តម លោកជំទាវ ដើម្បីការពារសារព័ត៌មានសេរី និងលំហូរព័ត៌មានដោយសេរីក្នុងពេលវេលាដ៏មានសារៈសំខាន់នេះ។ សារព័ត៌មានមិនត្រូវនាំមកនូវការអនុវត្តទោសប្រហារជីវិតទេ៕

ដោយភាពស្មោះត្រង់ពីយើងខ្ញុំ

Afghan Journalists Safety Committee

AGHS Legal Aid Cell

Alliance for Journalists' Freedom

Alliance of Independent Journalists Indonesia

Americans for Kashmir

Amnesty International India

ARTICLE 19

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA—ខេមបូចា)

Centre of Media Persons for Change, Chennai - India

CGNet Swara - India

Civil Rights Defenders

Coalition for Women in Journalism

Committee to Protect Journalists

Committee Against Assault on Journalists - India

Dhaka Tribune

Digital Rights Foundation

Federation of Nepali Journalists

Foreign Correspondents Club of Thailand

Freedom of Expression Myanmar

Free Media Movement

Freedom Forum

Freedom Network - Pakistan

Free Speech Collective - India

Hong Kong Free Press

Human Rights in China

Hyderabad Journalists Federation - India

Hyderabad Working Journalists Federation - India

Hyderabad Union of Working Journalists - India

Impulse Model Press Lab - India

Imphal Free Press - India

Independent Journalists Association of Vietnam

Indian Federation of Working Journalists

Indian Journalists Union

INFORM Human Rights Documentation Centre

Internet Freedom Foundation - India

Jammu Kashmir Coalition of Civil Society - India

Jansandesh Times - India

Journalists Union of Assam

Kashmir Working Journalists Association - India

Kashmir Times - India

Kerala Union of Working Journalists - India

Local Press Hong Kong

Malaysiakini

Media Action Nepal

Mumbai Press Club - India

Mumbai Patrakar Sangh - India

Nai Baat

National Union of Journalists of the Philippines

National Union of Journalists Peninsular Malaysia

New Bloom Magazine

New Naratif

Network of Women in Media India

Overseas Press Club of Cambodia

Pakistan Press Foundation

Park Center for Independent Media, Ithaca College

People's Vigilance Committee on Human Rights - India

People's Union for Civil Liberties - India

PEN Delhi - India

PEN Myanmar

Philippine Center for Investigative Journalism

Press Association - India

Radio Free Asia

Siasat Daily - India

South Asia Free Media Association - Sri Lanka

South Asian Journalists Association

South Asia Women in Media, Sri Lanka

Sri Lanka Working Journalists Association

Tamil Nadu Women Journalists Association - India

Talk Journalism, India

Telangana State Union of Working Journalists - India

Telangana Urdu Working Journalists Union - India

The 88 Project

The Irrawaddy

The Lede - India

The Reporter, Taiwan

Weiquanwang

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក ណុប វី នាយកប្រតិបត្តិសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)

០១២ ៥១៩ ២៦១

ed@camboja.net